ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩

## អគ្គនាយកដ្ឋានគោលនយោបាយ
## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែវិច្ឆិកា ឆ្នាំ២០១៩

# មាតិកា

I. សេចក្តីអធិប្បាយសង្ខេប ............ 1

II. ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ............ 4

**១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ** ............ 4

**២. សូចនាករតាមវិស័យ** ............ 5

២ .១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ............ 5

២អត្រាប្តូរប្រាក់ .៣. ............ 6

២ហិរញ្ញវ .៤. ត្ថុសាធារណៈ ............ 7

២រូបិយវត្ថុ .៥. ............ 8

២វិស័យពាណិជ្ជកម្ម .៦. ............ 9

២ការវិនិយោគឯកជន .៧. ............ 12

២វិស័យទេសចរណ៍ .៨. ............ 12

២វិស័យសំណង់ .៩. ............ 14

**៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ** ............ 14

III. ឧបសម្ព័ន្ធ ............ 16

# សេចក្តីអធិប្បាយសង្ខេប

សេដ្ឋកិច្ចសកល រំពឹងថានឹងមានកំណើនទាបក្នុងអត្រា ៣% ដោយសារការថមថយកំណើនសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក, ចិន និងតំបន់អឺរ៉ុប ២៨, បច្ច័យនៃសង្គ្រាមពាណិជ្ជកម្ម, ការប្រែប្រួលគោលនយោបាយរូបិយវត្ថុ និងភាពមិនប្រាកដប្រជានៃភូមិសាស្ត្រនយោបាយ ។ ទោះជាយ៉ាងណាក្តី, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ នៅបន្តភាពរឹងមាំ ដែលបានគាំទ្រដោយកម្រិតប្រែប្រួលទាបនៃអត្រាអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណអន្តរជាតិ ។ ទន្ទឹមនឹងភាពរឹងមាំនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងត្រីមាសទី៣, ទំហំវិនិយោគឯកជន និងសំណង់ ក៏មានសន្ទុះកំណើន ។ កំណើនទំហំពាណិជ្ជកម្ម ដែលជំរុញវិស័យលក់រាយនិងដុំ សម្រាប់ផលិតប្រើប្រាស់ក្នុងស្រុកនិងនាំចេញ បានបន្តគាំទ្រជាកំណើនសំខាន់ សម្រាប់ចំណូលសារពើពន្ធ និងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ។ **ឥណទានផ្តល់ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធៀបនឹង ផសស ប៉ាន់ស្មានថានឹងឈានដល់ ១១៨,៧%** (*) **ដែលបានឆ្លុះបញ្ចាំងពីតម្រូវការខ្ពស់ផ្នែកឥណទានសម្រាប់ចូលរួមបន្តជំរុញបណ្តាសកម្មភាពពាណិជ្ជកម្ម, បណ្តាផលិតកម្មសេដ្ឋកិច្ចក្នុងស្រុក, ការវិនិយោគ និងការប្រើប្រាស់គ្រួសារ ។**

**ការវិនិយោគឯកជន** (1)

ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសដែលអនុម័តដោយ CDC ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ មាន ៤៩ គម្រោង លើទុនវិនិយោគ ១ ១៥៣ លានដុល្លារអាមេរិក ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំ២០១៨ ដែលបន្តគាំទ្រដោយកំណើនខ្ពស់នៃការវិនិយោគក្នុងវិស័យទេសចរណ៍ ដូចជាសណ្ឋាគារ និងមជ្ឈមណ្ឌលទេសចរណ៍ តាមតំបន់ឆ្នេរសមុទ្រ ។ យ៉ាងណាក្តី, គម្រោងវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម បានបន្តធ្លាក់ចុះខ្លាំង ឬមានចំណែកត្រឹម ១% នៃគម្រោងវិនិយោគសរុប ប៉ុណ្ណោះ ។ **ជាការកត់សម្គាល់ក្នុងត្រីមាសទី៣ នេះផងដែរ, គម្រោងវិនិយោគទាំងអស់ គឺបានប្រើប្រាស់ទុនវិនិយោគក្រៅស្រុកទាំងស្រុង ។**

**សំណង់** (2)

**ការអភិវឌ្ឍសំណង់ពាណិជ្ជកម្ម, លំនៅឋាន, ឧស្សាហកម្ម និងទេសចរណ៍ ព្រមទាំងការនាំចូលសម្ភារសំណង់ នៅបន្តមានកំណើនខ្ពស់ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ ដែលអាចចូលរួមទ្រទ្រង់ដល់វិស័យសំណង់ ឱ្យកាន់តែរឹងមាំរហូតដំណាច់ឆ្នាំ២០១៩ ។** ការអនុម័តលើសំណើគម្រោងសាងសង់ មានចំនួន ១ ៣៨៦ គម្រោង លើទុនវិនិយោគ ៣ ១០២ លានដុល្លារអាមេរិក ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំ២០១៨ ក្នុងអត្រា ៥៤,៣% ។ កំណើននៃការផ្គត់ផ្គង់ទាំងអស់នេះ ក៏បានឆ្លុះ

---

[1] ប្រភពទិន្នន័យៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ចំណាំ (*) ÷ ទិន្នន័យឥណទានផ្តល់ដោយធនាគារពាណិជ្ជ មានដល់ខែ កញ្ញា ឆ្នាំ២០១៩ ។ រីឯទិន្នន័យឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺមានត្រឹមខែ សីហា ឆ្នាំ២០១៩ ។

[2] ប្រភពទិន្នន័យៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

បញ្ចាំងពីតម្រូវការ នាំចូលសម្ភារសំណង់ ពោលគឺបានបន្តកំណើនខ្ពស់ក្នុងអត្រា ៥៩,១% គិតជាបរិមាណ ។

**ទេសចរណ៍** (3)

វិស័យទេសចរណ៍ មានកំណើនថមថយបន្តិច ក្នុងត្រីមាសទី៣ **ឆ្នាំ២០១៩** បន្ទាប់ពីបានទ្រទ្រង់ដោយកំណើនយ៉ាងគំហុកនៃចំនួនអ្នកដំណើរទេសចរចិនកន្លងមក ។ អ្នកដំណើរទេសចរមកកម្ពុជា សរុបប្រមាណ ១,៤៧ លាននាក់ ក្នុងអត្រាកំណើន ៧,៤% ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៨ ដោយសារការបន្តធ្លាក់ចុះចំនួនអ្នកដំណើរទេសចរ មកពីតំបន់អាមេរិក (-៨,៣%) និងអឺរ៉ុប (-៦,៨%) និងកំណើនអ្នកដំណើរទេសចរ មកពីតំបន់អាស៊ី និងប៉ាស៊ីហ្វិក មាននិន្នាការថមថយ ។ **ចំនួនអ្នកដំណើរទេសចរ ក៏សង្កេតឃើញមានសញ្ញាណធ្លាក់ចុះ និងថមថយ ក្នុងបណ្តាប្រទេសមួយចំនួនក្នុងតំបន់ ដូចជា ថៃ និងសិង្ហបុរី គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩** ។

**ពាណិជ្ជកម្មក្រៅប្រទេស** (4)

ទំហំនាំចូល ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ មានកំណើន ១៩,៨% ទាបជាងត្រីមាសដូចគ្នា ឆ្នាំ២០១៨ ដោយសារការធ្លាក់ចុះនៃការនាំចូលផលិតផលវាយនភណ្ឌ ខណៈការនាំចូលផលិតផលសំខាន់មួយចំនួនទៀត ដូចជា យានយន្តនិងគ្រឿងចក្រ, ប្រេងឥន្ធនៈ, ទំនិញចម្រុះ និងគ្រឿងសំណង់ ដែលទ្រទ្រង់ចំណូលសារពើពន្ធ នៅតែបន្តរក្សាបានកំណើនខ្ពស់ ។ **ការនាំចូលវាយនភណ្ឌ សម្រាប់ឧស្សាហកម្មកាត់ដេរ បានធ្លាក់ចុះ (-១៨%) ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ ហើយការធ្លាក់ចុះនេះ ក៏ស្របនឹងនិន្នាការថមថយកំណើននៃការនាំចេញផលិតផលកាត់ដេរ ដែលអាចប្រឈមនឹងការបន្តថមថយកំណើន នៅក្នុងត្រីមាសទី៤ ខាងមុខនេះ ។**

ការនាំចេញរបស់កម្ពុជា ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ មានទំហំ ១៧ ៤២១ ប៊ីលានរៀល ក្នុងអត្រាកំណើន ១៥,៧% ទាបជាងត្រីមាសដូចគ្នា ឆ្នាំ២០១៨ ក្នុងនោះ ការនាំចេញផលិតផលកាត់ដេរ មានកំណើន ១៣,៨% បានថមថយពី ២០,៨% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ ។ កំណើនថមថយនៃការនាំចេញសរុប ត្រូវបានប៉ះប៉ូវវិញដោយកំណើនខ្ពស់នៃការនាំចេញផលិតផលឧស្សាហកម្មផ្សេងៗទៀត ដូចជា គ្រឿងបង្គុំ និងកង់ ក្នុងអត្រា ៩១,៣% និង ២៧,៧% ។ **គួសបញ្ជាក់ថា ផលិតផលនាំចេញទៅទីផ្សារអាមេរិក ទាំងក្នុងនិងក្រៅប្រព័ន្ធអនុគ្រោះពន្ធ សម្រេចបាន ១ ៤០១ លានដុល្លារ ក្នុងអត្រាកំណើន ៥២,៨% ខ្ពស់ជាងត្រីមាសដូចគ្នា ឆ្នាំ២០១៨** ។

3 ប្រភពទិន្នន័យៈ ក្រសួងទេសចរណ៍

4 ប្រភពទិន្នន័យ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទិន្នន័យនាំចេញ-នាំចូល នឹងមានការកែសម្រួល

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ** [5]

យោងតាមទិន្នន័យបឋមពីអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ នេះ ការប្រមូលចំណូលចរន្តសរុបនៅរដ្ឋបាលថ្នាក់ជាតិ អនុវត្តបាន ៦ ២៦៦ ប៊ីលានរៀល ក្នុងនោះ ធៀបនឹងចំណូលចរន្តសរុប, ចំណូលសារពើពន្ធមាន ៨៥,៩% ។ ក្នុងន័យនេះ អតិរេកចរន្ត ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ មានចំនួន ២ ២៥៦ ប៊ីលានរៀល ។ **ចំណូលចរន្តសរុបត្រឹមដំណាច់ត្រីមាសទី៣ ឆ្នាំ២០១៩ អនុវត្តបាន ៩០,១% នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ។**

**ប្រតិបត្តិការរូបិយវត្ថុ និងឥណទាន** [6]

អត្រារូបិយវត្ថុទូទៅ ធៀបនឹង ផសស បានឈានដល់ ៩៣,៨% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ ដោយកើនពី ៨៥,៧% ក្នុងត្រីមាសដូចគ្នាឆ្នាំ២០១៨ ។ ទន្ទឹមនេះ ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ បានឈានដល់ ១០១ ៤៤៥ ប៊ីលានរៀល ក្នុងអត្រាកំណើន ២៧,៣% ខ្ពស់ជាង ត្រីមាសដូចគ្នាឆ្នាំ២០១៨ ដែលមានអត្រា ២២,៦% ។ **កំណើនតម្រូវការឥណទានត្រូវបានឆ្លុះបញ្ចាំងដោយអត្រាកំណើនខ្ពស់ ក្នុងសកម្មភាពសំណង់, ការជួញដូរដុំនិងរាយ និងតម្រូវការផ្ទាល់ខ្លួន ។ យ៉ាងណាក្តី ការផ្តល់ឥណទានទៅបណ្តាសកម្មភាពសេដ្ឋកិច្ច មានសញ្ញាណថមថយ ក្នុងខែកញ្ញា ឆ្នាំ២០១៩ ធៀបនឹងខែសីហា ឆ្នាំ២០១៩ ។**

**អតិផរណា និង អត្រាប្តូរប្រាក់** [7]

អតិផរណាក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ ស្ថិតនៅកម្រិតទាប ពោលគឺជាមធ្យមក្នុងអត្រា ២,០% ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៨ ដែលមានអត្រា ២,៤% ដោយសារកំណើនចំណាយទាបនៃក្រុមអាហារ-ភេសជ្ជៈមិនមានជាតិស្រវឹង ២,៤% និងការដឹកជញ្ជូន (-១,៦%) ។ **រយៈពេលដូចគ្នានេះ, អត្រាប្តូរប្រាក់ ជាមធ្យម ៤ ០៨៦ រៀល/ដុល្លារអាមេរិក ។**

---

[5] ទិន្នន័យបណ្តោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ ដែលពុំទាន់បានកត់ត្រាទាំងស្រុង ឬបច្ចុប្បន្នភាពទិន្នន័យនៅត្រីមាសក្រោយៗ

[6] ប្រភពទិន្នន័យ÷ ធនាគារជាតិ នៃកម្ពុជា

[7] ប្រភពទិន្នន័យ÷ វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **សូចនាករមូលដ្ឋាន** | | | | |
| ផសស ថ្លៃបច្ចុប្បន្ន -- (ប៉ាន់ស្មានឆ្នាំ២០១៩) | ប៊ីលានរៀល | 89,754 | 98,786 | 108,590 |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 3.3% | 2.4% | 2.0% |
| អត្រាប្តូរប្រាក់រៀល/ ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,080 | 4,073 | 4,086 |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 3,882 | 4,626 | 6,266 |
| ចំណាយចរន្ត | ប៊ីលានរៀល | (3,219) | (3,883) | (4,010) |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 664 | 742 | 2,256 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| កំណើនរូបិយវត្ថុទូទៅ | % | 22.1% | 21.3% | 20.4% |
| អត្រារូបិយវត្ថុទូទៅ | % នៃ ផសស | 77.7% | 85.7% | 93.8% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំហំនាំចេញ | ប៊ីលានរៀល | 12,674 | 15,058 | 17,421 |
| ទំហំនាំចូល | ប៊ីលានរៀល | (18,259) | (17,811) | (21,330) |
| តុល្យភាពពាណិជ្ជកម្ម | ប៊ីលានរៀល | (5,585) | (2,753) | (3,909) |
| **វិនិយោគឯកជន (១)** | | | | |
| គម្រោង | ចំនួន | 38 | 29 | 49 |
| ទុនវិនិយោគ | លានដុល្លារ | 3,005 | 1,059 | 1,153 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | ពាន់នាក់ | 1,250 | 1,374 | 1,476 |
| **វិស័យសំណង់** | | | | |
| គម្រោងអនុញ្ញាត | ចំនួន | 999 | 898 | 1,386 |
| តម្លៃសំណង់ | លានដុល្លារ | 692 | 2,667 | 3,102 |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ** | | | | |
| អង្ករ | ដុល្លារ/ តោន | 441 | 427 | 420 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/ បារ៉ែល | 47 | 75 | 63 |
| កៅស៊ូ | ដុល្លារ/ តោន | 1,720 | 1,560 | 1,927 |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

សម្គាល់ (១) ÷ មិនរួមបញ្ចូលគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេស

*រូបភាព 1 ÷ ស្ថានភាពសូចនាករសេដ្ឋកិច្ចសំខាន់ៗ*




ប្រភពៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

## ២. សូចនាករតាមវិស័យ

### ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី៣)*

| សូចនាករ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **មុខទំនិញគ្រប់មុខ** | 168.6 | 173.0 | 176.5 |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 205.3 | 210.5 | 214.9 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 159.2 | 161.0 | 169.9 |
| សម្លៀកបំពាក់ និង ស្បែកជើង | 143.5 | 146.7 | 150.7 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 124.4 | 125.7 | 127.4 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 150.0 | 150.5 | 152.1 |
| សុខាភិបាល | 132.7 | 134.8 | 136.9 |
| ការដឹកជញ្ជូន | 111.6 | 116.1 | 114.2 |
| គមនាគមន៍ | 68.2 | 67.7 | 67.3 |
| ការកំសាន្ត និងវប្បធម៌ | 119.0 | 118.1 | 119.2 |
| ការសិក្សា | 160.1 | 159.4 | 159.6 |
| ភោជនីយដ្ឋាន | 248.6 | 266.0 | 282.9 |
| ទំនិញ និងសេវាកម្មផ្សេងៗ | 140.1 | 144.3 | 146.3 |

ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 2÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាសទី៣)*




ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |
| 2018 | 4,012 | 4,046 | 4,073 | 4,047 |
| 2019 | 4,006 | 4,052 | 4,086 | |

ប្រភពៈ ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ត្រីមាសទី៣*

| ប៊ីលានរៀល | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| I. ចំណូលក្នុងប្រទេស | 3,923 | 4,670 | 6,321 |
| ១. ចំណូលចរន្ត | 3,882 | 4,626 | 6,266 |
| ក. ចំណូលសារពើពន្ធ | 3,323 | 4,010 | 5,385 |
| ខ.ចំណូលមិនមែនសារពើពន្ធ | 559 | 615 | 881 |
| ២. ចំណូលមូលធន | 40 | 45 | 55 |
| II. ចំណាយសរុប | 4,809 | 5,861 | 5,348 |
| ១. ចំណាយចរន្ត | 3,211 | 3,883 | 4,010 |
| ក. ការពារ និងសន្តិសុខជាតិ | 733 | 982 | 947 |
| ខ. រដ្ឋបាលស៊ីវិល | 2,346 | 2,742 | 2,889 |
| គ. ចំណាយការប្រាក់ | 133 | 159 | 174 |
| ២. ចំណាយមូលធន | 1,598 | 1,978 | 1,338 |
| ឱនភាពចរន្ត (សាច់ប្រាក់) | 645 | 742 | 2,256 |
| ឱនភាពទូទៅ (សាច់ប្រាក់) | (913) | (1,191) | 973 |
| III. ហិរញ្ញប្បទាន | 913 | 1,191 | (973) |
| ១. ហិរញ្ញប្បទានក្រៅស្រុក | 1,054 | 413 | 607 |
| ២. ហិរញ្ញប្បទានក្នុងស្រុក | 66 | (36) | (1) |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | (208) | 814 | (1,579) |

ប្រភព៖ អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. រូបិយវត្ថុ

*តារាង 5 ÷ ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី៣*

| (ប៊ីលានរៀល) | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ទ្រព្យសកម្មបរទេសសុទ្ធ | 43,302 | 52,669 | 66,873 |
| ទ្រព្យសកម្មបរទេស | 60,434 | 69,633 | 88,006 |
| ទ្រព្យអកម្មបរទេស | (17,133) | (16,963) | (21,133) |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 26,440 | 31,942 | 35,023 |
| ឥណទានក្នុងស្រុក | 53,145 | 64,931 | 78,058 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (10,348) | (12,996) | (20,263) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 63,493 | 77,927 | 98,321 |
| ទ្រព្យសកម្មផ្នែកផ្សេងៗ | (26,705) | (32,989) | (43,035) |
| ប្រាក់បញ្ញើហាមឃាត់ | (1,510) | (1,927) | (2,298) |
| មូលធន និងធនបម្រុង | (21,918) | (26,277) | (34,143) |
| ផ្សេងៗ | (3,277) | (4,785) | (6,594) |
| រូបិយវត្ថុទូទៅ (M2) | 69,742 | 84,611 | 101,896 |
| រូបិយវត្ថុ (M1) | 8,925 | 10,146 | 13,466 |
| *រូបិយវត្ថុក្រៅធនាគារ* | 7,987 | 9,200 | 12,049 |
| *ប្រាក់បញ្ញើចរន្ត* | 938 | 946 | 1,417 |
| រូបិយវត្ថុផ្សេងៗ | 60,817 | 74,465 | 88,430 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | 2,554 | 3,212 | 4,033 |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | 58,263 | 71,253 | 84,397 |
| ទុនបម្រុងរូបិយបណ្ណបរទេសសុទ្ធ (លានដុល្លារ) | 8,361 | 9,271 | 12,406 |

ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*រូបភាព 3 ÷ ទំហំនាំចូលបរិក្ខារសំណង់, ទោចក្រ-យានយន្ត និងវាយនភណ្ឌ (គិតជាប៊ីលានរៀល)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 6 ÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ថ្នាំពេទ្យ | 158 | 204 | 223 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 471 | 644 | 657 |
| ស្ករស និងប៊ីចេង | 50 | 36 | 40 |
| ប្រេងឆា និងអាហារផ្សេងៗ | 310 | 407 | 559 |
| សម្ភារសំណង់ | 659 | 1,075 | 1,762 |
| អេឡិចត្រូនិច | 10 | 122 | 128 |
| វាយនភណ្ឌ | 4,030 | 5,035 | 4,128 |
| ទោចក្រ-យានយន្ត | 1,013 | 1,329 | 2,220 |
| គ្រឿងបន្លាស់យានយន្ត | 14 | 27 | 41 |
| បរិក្ខារត្រជាក់ | 73 | 82 | 126 |
| មាស | 140 | 710 | - |
| ប្រេងឥន្ធនៈ | 867 | 1,213 | 1,819 |
| ជីកសិកម្ម | 346 | 231 | 253 |
| ផ្សេងៗ | 6,499 | 6,695 | 9,375 |
| **សរុប** | 14,640 | 17,811 | 21,330 |

ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 4 ÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាប៊ីលានរៀល)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 5 ÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 7÷ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)

| មុខទំនិញ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| សម្លៀកបំពាក់ | 8,305 | 9,370 | 9,996 |
| ស្បែកជើង | 842 | 1,101 | 1,299 |
| វាយនភណ្ឌផ្សេងៗ | 197 | 817 | 1,550 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 335 | 167 | 345 |
| គ្រឿងបង្គុំរថយន្ត | 5 | 62 | 93 |
| កង់ | 319 | 363 | 463 |
| ឈើមូល | 14 | 149 | 26 |
| ក្តារបន្ទះ | 0 | 20 | 138 |
| ផលិតផលផ្សេងៗពីឈើ | 121 | 6 | 8 |
| អង្ករ | 271 | 361 | 345 |
| កៅស៊ូ | 293 | 243 | 245 |
| ស្ករស | 49 | 111 | 86 |
| ផលិតផលកសិកម្មផ្សេងៗ | 51 | 164 | 98 |
| បារី | 16 | 23 | 17 |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 0 | 173 | 236 |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0 | 9 | 2 |
| ផលិតផលផ្សេងៗ | 1,857 | 1,918 | 2,472 |
| **នាំចេញសរុប** | 12,674 | 15,058 | 17,421 |

ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៧. ការវិនិយោគឯកជន

*តារាង 8 ÷ ស្ថិតិវិនិយោគវិស័យឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| គម្រោង | ចំនួន | 38 | 29 | 49 |
| បង្កើតការងារ | ការងារ | 46,374 | 54,809 | 42,612 |
| ទុនវិនិយោគលើវិស័យ | | | | |
| កសិកម្ម | លានដុល្លារ | 206 | 32 | 10 |
| ឧស្សាហកម្ម | លានដុល្លារ | 281 | 408 | 272 |
| សេវាកម្ម | លានដុល្លារ | 0 | 550 | 0 |
| ទេសចរណ៍ | លានដុល្លារ | 2,519 | 68 | 871 |
| **សរុប** | **លានដុល្លារ** | 3,005 | 1,059 | 1,153 |
| ទុនវិនិយោគក្នុងស្រុក | លានដុល្លារ | 2,550 | 769 | 0 |
| ទុនវិនិយោគបរទេស | លានដុល្លារ | 455 | 290 | 1,153 |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៨. វិស័យទេសចរណ៍

*តារាង 9 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា*

| សូចនាករ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **សរុប** | 1,250,082 | 1,374,373 | 1,475,832 |
| តាមផ្លូវអាកាស | 777,745 | 954,798 | 1,039,862 |
| ភ្នំពេញ | 359,191 | 464,217 | 485,967 |
| សៀមរាប | 393,967 | 425,995 | 325,048 |
| កងកេង | 24,587 | 64,586 | 228,847 |
| តាមផ្លូវគោក និងផ្លូវទឹក | 472,337 | 419,575 | 435,970 |
| ផ្លូវគោក | 453,593 | 396,481 | 420,231 |
| ផ្លូវទឹក | 18,744 | 23,094 | 15,739 |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព 6 ÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

*រូបភាព 7 ÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 10 ÷ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 999 | 898 | 1,386 |
| តម្លៃសាងសង់ | លានដុល្លារ | 692 | 2,667 | 3,102 |
| **គម្រោងសុំសាងសង់តាមប្រភេទសំណង់** | | | | |
| សាធារណៈ | ចំនួន | 18 | 6 | 30 |
| លំនៅឋាន និងភូមិគ្រឹះ | ចំនួន | 820 | 744 | 1,138 |
| ឧស្សាហកម្ម | ចំនួន | 37 | 24 | 74 |
| សំណង់ពាណិជ្ជកម្ម | ចំនួន | 79 | 85 | 95 |
| សំណង់ទេសចរណ៍ | ចំនួន | 43 | 34 | 42 |
| សំណង់វិនិយោគផ្សេងៗ | ចំនួន | 2 | 5 | 7 |
| **សរុប** | ចំនួន | 999 | 898 | 1,386 |

ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 11 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី៣ | | |
|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ |
| អង្ករ | តោន/ ដុល្លារ | បាងកក | 385 | 405 | 427 |
| ប្រេងឆៅ Brent | ធុង/ ដុល្លារ | ក្រុងឡុងដ៍ | 55 | 79 | 62 |
| កៅស៊ូ | តោន/ ដុល្លារ | សិង្ហបុរី | 1,858 | 1,442 | 1,499 |
| មាស | អោន/ ដុល្លារ | ហុងកុង | 1,442 | 1,315 | 1,657 |
| ពោតក្រហម | តោន/ ដុល្លារ | ស៊ីកាហ្គោ | 147 | 155 | 157 |
| សណ្តែកសៀង | តោន/ ដុល្លារ | ស៊ីកាហ្គោ | 397 | 357 | 366 |
| ប្រេងដូង | តោន/ ដុល្លារ | រ៉ុតធើដាំ | 1,525 | 908 | 724 |
| ស្ករស | តោន/ ដុល្លារ | ក្រុងឡុងដ៍ | 389 | 381 | 359 |

ប្រភព៖ គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 12 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ប្រេងឥន្ធនៈ | 53 | 75 | 60 |
| ផលិតផលកសិកម្ម | 88 | 83 | 81 |
| ម្ហូបអាហារ | 91 | 86 | 84 |
| ឈើ | 88 | 86 | 84 |
| ជីគីមី | 74 | 87 | 78 |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 13 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ជប៉ុន (យ៉េន) | 106.22 | 113.68 | 107.90 |
| ហុងកុង (ដុល្លារ) | 7.85 | 7.83 | 7.84 |
| សិង្ហបុរី (ដុល្លារ) | 1.31 | 1.37 | 1.38 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.86 | 4.14 | 4.19 |
| ហ្វីលីពីន (ប៉េសូ) | 52.16 | 53.88 | 51.79 |
| ថៃ (បាត) | 31.13 | 32.18 | 30.49 |
| ឥណ្ឌូនេស៊ី (រូព្យា) | 13,732.50 | 14,899.00 | 14,184.50 |
| កូរ៉េ (វ៉ុន) | 1,061.17 | 1,109.32 | 1,202.00 |
| តៃវ៉ាន់ (ដុល្លារ) | 29.08 | 30.45 | 31.03 |
| ចិន (រ៉េនមីនប៊ី) | 6.28 | 6.87 | 7.12 |
| ឡាវ (គីប) | 3,973.61 | 4,072.50 | 4,069.00 |
| វៀតណាម (ដុង) | 8,236.54 | 8,502.50 | 8,703.92 |
| ឥណ្ឌា (រូពី) | 22,741.30 | 23,318.50 | 23,153.70 |
| រុស្ស៊ី (រូប) | 64.92 | 72.33 | 70.34 |
| អូស្ត្រាលី (ដុល្លារ) | 57.23 | 65.56 | 64.62 |
| អង់គ្លេស (ផោន) | 1.30 | 1.38 | 1.48 |
| អឺរ៉ុប (អឺរ៉ូ) | 0.71 | 0.77 | 0.81 |

ប្រភពៈ OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 14÷ ស្ថិតិកសិកម្ម*

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| ផ្ទៃដីដាំដុះ | | | | |
| ស្រូវ | ហិកតា | 2,609,617 | 2,728,274 | 2,626,460 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 869,383 | 923,838 | 906,002 |
| កៅស៊ូ | ហិកតា | 432,096 | 427,000 | 434,552 |
| ផ្ទៃដីប្រមូលផល | | | | |
| កៅស៊ូ | ហិកតា | 163,132 | 201,000 | 233,212 |
| បរិមាណផល | | | | |
| កៅស៊ូ (ក្រែប) | តោន | 123,643 | 139,474 | 175,280 |
| ជលផល | តោន | 527,483 | 567,668 | 595,978 |

ប្រភពៈ របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

*រៀបចំដោយនាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ*

*ទំនាក់ទំនងៈ*

*Email: sead@mef.gov.kh*